00640105

E24

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១១

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 25 / 01 / 2011
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើបន្ទាន់របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធស្នើសុំឲ្យមានការបន្ថែមពេលវេលា និង ចំនួនទំព័រ សំរាប់អញ្ញត្រកម្ម

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់ អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ្រ អង្គ

Elisabeth SIMONNEAU FORT

## I. សេចក្ដីផ្ដើម និង សំណើ

១. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, អង្គបុរេជំនុំជម្រះបានចេញ "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ"[1] (**សាលដីការបស់ អបជ**) ហើយដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្ដឹងនូវសំណុំរឿងលេខៈ ០០២។ នៅថ្ងៃបន្ទាប់គឺនៅថ្ងៃទិ ១៤ ខែ មករា ឆ្នាំ ២០១១, មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធ (ជនជាប់ចោទ) បានដាក់ " សំណើបន្ទាន់ដើម្បីកំណត់អំពីកាលបរិច្ឆេទកំណត់" (**សំណើអំពីការបញ្ជាក់ថ្ងៃផុតកំណត់**)[2]

២. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, អង្គជំនុំជម្រះសាលាដំបូងបានចេញ "ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ"[3] (**ដីកា**) ។

៣. នៅក្នុងសំណើអំពីកាលបរិច្ឆេទកំណត់, មេធាវីការពារក្ដីបានលើកឡើងថា សាលដីការបស់អង្គបុរេជំនុំជម្រះមិនមានគុណសម្បត្តិជា "ដីកាសម្រេច" ដូចដែលបានកំណត់នៅក្នុងវិធាន ៧៧(១៤)នៃវិធានផ្ទៃក្នុង ដែលតម្រូវឲ្យមានសំអាងហេតុនោះ ដូចដែលបានពន្យល់ដោយអង្គបុរេជំនុំជម្រះនៅក្នុងសាលដីការបស់ខ្លួនថាៈ

> អង្គបុរេជំនុំជម្រះបានសម្រេចជាស្ថាពរលើបណ្ដឹងឧទ្ធរណ៍ ដូចដែលអង្គបុរេជំនុំជម្រះប្រកាសនៅពេលនេះ។ ការចេញសំអាងហេតុសម្រាប់គាំទ្រសាលដីកានេះនឹងធ្វើទៅតាមពេលវេលាសមស្រប។ [4]

៤. នៅក្នុងសំណើអំពីកាលបរិច្ឆេទកំណត់, មេធាវីការពារក្ដីបានលើកឡើងថា កាលបរិច្ឆេទកំណត់នៅក្នុងវិធាន ៨០ និង ៨៩ នៃវិធានផ្ទៃក្នុង មិនទាន់ចាប់ផ្ដើមគិតនៅឡើយទេ លុះត្រាតែ អង្គបុរេជំនុំជម្រះបានចេញនូវសំអាងហេតុរបស់ខ្លួនចំពោះសាលដីកាសម្រេចនោះសិន។

---

[1] អបជ, សាលដីលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខៈ D427/2/12 ។

[2] សំណើបន្ទាន់របស់មេធាវីការពារក្ដីដើម្បីកំណត់អំពីកាលបរិច្ឆេទកំណត់, ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខៈ E14 ។

[3] អជជសដ, ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខៈ E9 ។

[4] ទំព័រ ៥នៃ សាលដីកាសម្រេចរបស់អង្គបុរជំនុំជម្រះ ។

៥. អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចទៅលើសំណើអំពីកាលបរិច្ឆេទកំណត់របស់មេធាវីការពារក្តីនៅឡើយទេ ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញនូវគោលជំហររបស់ខ្លួនអំពីកាលបរិច្ឆេទកំណត់ថា:

> រយៈពេលកំណត់នេះត្រូវចាប់គិតពីថ្ងៃសុក្រ ទី ១៤ ខែ មករា ឆ្នាំ ២០១១ ជាថ្ងៃដែលក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងជាផ្លូវការពីអង្គបុរេជំនុំជម្រះ។[5]

៦. សំណើនេះតាក់តែងឡើងដោយផ្អែកទៅលើសំណើអំពីការកំណត់កាលបរិច្ឆេទ ដែលនៅក្នុងស្មារតីនេះ មេធាវីការពារក្តីសូមស្នើថា អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យបន្ថែមពេលវេលាដល់មេធាវីការពារក្តីដើម្បីតាក់តែងនូវអញ្ញត្រកម្មរបស់ខ្លួនដូចមានចែងនៅក្នុងវិធាន ៨៩ នៃវិធានផ្ទៃក្នុងបន្ទាប់ពីបានទទួលនូវសេចក្តីសម្រេចដែលមានសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ។

៧. លើសពីនេះទៀតនោះ មេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យមេធាវីការពារក្តីបន្ថែមនូវចំនួនទំព័រដើម្បីតាក់តែងនូវអញ្ញត្រកម្មរបស់ខ្លួន។

## II **បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ**

៨. វិធាន ៨៩ នៃវិធានផ្ទៃក្នុង បានចែងនូវចំណុចដែលពាក់ព័ន្ធថា:

> អញ្ញត្រកម្មទាក់ទងនឹង:
>
> ក)យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង
>
> ខ)ការរលត់បណ្តឹងអាជ្ញា
>
> គ)មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយត្រូវលើកឡើងយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ។

៩. វិធាន ៣៩(៤)(ក)នៃវិធានផ្ទៃក្នុងបានចែងថា: តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះអាច: ក)ពន្យាពេលវេលាកំណត់ដែលខ្លួនសម្រេច [.....]។

១០. មាត្រា ៥.១ នៃសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារនៅចំពោះមុខ អវតក បានចែងថា: “ឯកសារដែលត្រូវដាក់នៅ [......] អង្គជំនុំជម្រះសាលាដំបូងនៃអវតកមិនត្រូវលើសពី ១៥ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ ៣០ ទំព័រជាភាសាខ្មែរ លើកលែងតែមានសេចក្តីសម្រេចផ្សេងពី

---

[5] កថាខណ្ឌ ២ នៃដីកាបង្គាប់ ។

នេះដោយតុលា"។ មាត្រា ៥.៤ ចែងថា: "[...] តុលាការអាចសម្រេចទៅតាមពាក្យស្នើសុំរបស់ភាគីឲ្យបន្ថែមចំនួនទំព័រកំណត់បាននៅក្នុងកាលៈទេសៈពិសេស"។

## III. សេចក្តីសន្និដ្ឋាន

### ៣.១ សំណើសុំពន្យាកាលបរិច្ឆេទផុតកំណត់

១១. មេធាវីការពារក្តីយល់ឃើញថា: សាមសិប(៣០)ថ្ងៃដែលបានផ្តល់នៅក្នុងវិធាន ៨៩ នៃវិធានផ្ទៃក្នុង គឺមិនគ្រប់គ្រាន់ដើម្បីតាក់តែងអញ្ញត្រកម្មនោះទេ។

១២. នៅក្នុងកំឡុងពេលនេះ មេធាវីការពារក្តីត្រូវបានគេតម្រូវឲ្យដាក់នូវឯកសារជាច្រើនទៀតក្រៅពីឯកសារនោះដូចបានបញ្ជាក់តាមរយៈដីកាបង្គាប់ដោយបានកំណត់នូវកាលបរិច្ឆេទផុតកំណត់។ ម្យ៉ាងវិញទៀត ការបកប្រែឯកសារជាច្រើនត្រូវប្រើពេលវេលាយ៉ាងច្រើនថ្ងៃទៀតផងដែរ។ សារៈសំខាន់នៃអញ្ញត្រកម្មមិនអាចត្រូវបានគេបំផ្លើសឡើយដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងថា: ប្រសិនបើអញ្ញត្រកម្មត្រូវបានលើកឡើងនៅដំណាក់កាលចុងក្រោយនៃដំណើការនីតិវិធីនោះ "វាមិនអាចត្រូវបានទទួលយកបានឡើយ"។ ហេតុដូច្នេះ វាត្រូវតែចំបាច់បំផុតដែលមេធាវីការពារក្តីត្រូវបានគេផ្តល់នូវឱកាសដើម្បីវាយតម្លៃឲ្យបានហ្មត់ចត់នូវអញ្ញត្រកម្មនេះដែលមេធាវីការពារក្តីមានបំណងចង់លើកឡើងនោះ។

១៣. លើសពីនេះទៀតនោះ ខ្លឹមសារនៃអញ្ញត្រកម្មជាពិសេសចំពោះបញ្ហាដែលពាក់ព័ន្ធនឹងយុត្តាធិការដែលនឹងត្រូវពឹងផ្អែកទៅលើសំអាងហេតុនោះដែលអង្គបុរេជំនុំជម្រះមិនទាន់បានផ្តល់ដើម្បីគាំទ្រទៅលើសាលដីការបស់ខ្លួននៅឡើយទេ។ សួរថាតើមេធាវីការពារក្តីអាចរំពឹងគិតដើម្បីតាក់តែងអំណះអំណាងយ៉ាងដូចម្តេចចំពោះបញ្ហានេះបានដែរទេ នៅពេលដែលភាគីមិនអាចដឹងអំពីអំណះអំណាងនៅក្នុងដីកាដំណោះស្រាយស្ពានោះនៅឡើយ?

១៤. វិធាន ៨៩ នៃវិធានផ្ទៃក្នុងបានអនុញ្ញាតឲ្យមេធាវីការពារក្តីលើកឡើងនូវយុត្តាធិការនៃអង្គជំនុំជម្រះគឺជាអញ្ញត្រកម្ម។ អង្គបុរេជំនុំជម្រះកាលពីពេលមុនៗបានទទួលស្គាល់ថា "ភាពស្មុគស្មាញនៃបញ្ហាយុត្តាធិការជាច្រើនដែលត្រូវលើកឡើង"នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះ

ស្រាយ ហើយដែលភាពស្មុគស្មាញទាំងនោះនាំឱ្យមាន "កាលៈទេសៈពិសេស"[6]។ មេធាវីការពារក្តីយល់ឃើញថាបញ្ហាយុត្តាធិការដែលនឹងត្រូវលើកឡើងដោយមេធាវីការពារក្តីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះនឹងគ្មានមន្ទិលសង្ស័យថាមិនមែនជារឿងស្មុគស្មាញដូចបញ្ហាយុត្តាធិការដែលបានលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះអញ្ចឹងដែរ ហើយថាវានឹងបង្កើតឱ្យមានជាកាលៈទេសៈពិសេសដែលតម្រូវឱ្យមានការបន្ថែមនូវពេលវេលា។

១៥. មេធាវីការពារក្តីយល់ឃើញថាវាជាជំនួយដល់អង្គជំនុំជម្រះសាលាដំបូងផងដែរក្នុងការឱ្យមានការដោះស្រាយនូវបញ្ហាទាំងនេះដោយពេញលេញនិងពីស្តារនៅមុនការចាប់ផ្តើមនៃសវនាការជំនុំជម្រះក្តីនោះ។ អាស្រ័យហេតុនេះ មេធាវីការពារក្តី សូមស្នើដាក់នូវអញ្ញត្រកម្មរបស់ខ្លួននៅក្នុងរយៈពេលហុកសិប(៦០)ថ្ងៃបន្ទាប់ពីបានទទួលនូវសាលដីកាដែលមានសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ។

## ៣.២ សំណើសុំបន្ថែមចំនួនទំព័រ

១៦. មេធាវីការពារក្តីយល់ឃើញបន្ថែមទៀតថា ចំនួន ១៥ ទំព័រដែលបានអនុញ្ញាតដោយសេចក្តីណែនាំអនុវត្តគឺវាមិនគ្រប់គ្រាន់ទេដើម្បីដោះស្រាយជាមួយនឹងអញ្ញត្រកម្មនោះដោយមាននូវការជំទាស់នឹងយុត្តាធិការ បញ្ហាផ្សេងៗទៀតដែលនឹងតម្រូវឱ្យមានការបញ្ចប់នូវការផ្តន្ទាទោស និងមោឃភាពនៃកិច្ចនីតិវិធីនោះ។

១៧. ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី ១៣ និង ១៤ខាងលើ សារៈសំខាន់នៃឯកសារបែបនេះមិនអាចត្រូវបានបំផ្លើសឡើយឬថាភាពស្មុគស្មាញនេះមិនត្រូវគេបដិសេធនោះទេ។ ការបន្ថែមចំនួនទំព័រនឹងរឹតតែបង្កើននូវគុណភាពនៃឯកសារដែលត្រូវមានអំណាងអំណាងផ្សេងៗដើម្បីដាក់បញ្ចូលនៅក្នុងឯកសារនោះ។

---

[6] អង្គបុរេជំនុំជម្រះ, សាលដីកាលើសំណើសុំរបស់សហព្រះរាជអាជ្ញាដើម្បីដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងឧទ្ធរណ៍ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ហើយនិងបន្ទាប់មកបានបន្ថែមចំនួនទំព័រ, ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០,ឯកសារលេខ: D427/1/8 កថាខណ្ឌ ១៥
ដោយយោងទៅនឹងសាលដីកាលើសំណើបន្ទាន់របស់មេធាវីការពារក្តី លោក អៀង ធីរិទ្ធស្នើសុំបន្ថែមចំនួនទំព័រសំរាប់បណ្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១ ខែតុលា ឆ្នាំ ២០១០, ឯកសារលេខ: D427/1/3 កថាខណ្ឌ ១០។

១៨. មេធាវីការពារក្ដីសូមស្នើអង្គជំនុំជម្រះសាលាដំបូងដើម្បីអនុញ្ញាតបន្ថែមចំនួន សាមសិប(៣០)ទំព័រ ដើម្បីតាក់តែងនូវការជំទាស់តវ៉ាទាំងនេះ ហេតុនេះចំនួនទំព័រសរុបគឺ ៤៥ទំព័រសំរាប់អញ្ញត្រកម្ម ទាំងនោះ។

## IV សំណូមពរ

១៩. ដូច្នេះ យោងតាមមូលហេតុដែលបានគូសបញ្ជាក់នៅខាងលើ មេធាវីការពារក្ដីសូមស្នើ អង្គជំនុំជម្រះសាលាដំបូងដើម្បីអនុញ្ញាតឲ្យមេធាវីការពារក្ដីដូចខាងក្រោម:

ក. ដាក់អញ្ញត្រកម្មរបស់ខ្លួន នៅក្នុងរយៈពេលហុកសិប(៦០)ថ្ងៃបន្ទាប់ពីបានទទួលនូវ សំអាងហេតុរបស់អង្គបុរេជំនុំជម្រះ និង

ខ. បន្ថែមចំនួនទំព័រសរុប ចំនួន ៤៥ទំព័រដើម្បីតាក់តែងអញ្ញត្រកម្ម ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [signature and stamp: មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA] |